នស/រកត/០១០៨/០៣៩

# ព្រះរាជក្រឹត្យ

## ស្តីពី

## របបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល

### យើង

### ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
### សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
### ខេមរាជនា សមូហោភាស កម្ពុជឯករាជរជ្ជបូរណសន្តិ សុភមង្គលា សិរីវិបុលា
### ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលក្ខន្តិកគតិយុត្តនៃគ្រឹះស្ថានសាធារណរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

# ត្រាស់បង្គាប់

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ព្រះរាជក្រឹត្យនេះ មានគោលដៅកំណត់ពីរបបសន្តិសុខសង្គម ស្ថាប័នអនុវត្ត និងមូលនិធិសម្រាប់ទ្រទ្រង់របបសន្តិសុខសង្គម សម្រាប់មន្ត្រីរាជការស៊ីវិល ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.-**

របបសន្តិសុខសង្គមគ្របដណ្តប់លើតាវកាលិក ដូចខាងក្រោម :

- ការចូលនិវត្តន៍
- ការបាត់បង់សម្បទាវិជ្ជាជីវៈ
- មាតុភាព
- គ្រោះថ្នាក់ការងារ
- មរណភាព និង
- អ្នកនៅក្នុងបន្ទុក ។

**មាត្រា ៣.-**

មន្ត្រីរាជការស៊ីវិលជាសមាជិកនៃ **ប.ជ.ស.** ។

សិទ្ធិវន្តនៃរបបសន្តិសុខសង្គម រួមមានមន្ត្រីរាជការស៊ីវិល និវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ និងអ្នកនៅក្នុងបន្ទុករបស់ជនទាំងនេះ ។

## ជំពូកទី ២

## ស្ថាប័នអនុវត្ត

**មាត្រា ៤.-**

ការគ្រប់គ្រង និងការផ្តល់របបសន្តិសុខសង្គម ត្រូវស្ថិតនៅក្រោម "**បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល**" សរសេរកាត់ថា "**ប.ជ.ស.**" ដែលជាគ្រឹះស្ថានសាធារណរដ្ឋបាល ដែលត្រូវបានបង្កើតឡើងដោយអនុក្រឹត្យ ។

**មាត្រា ៥.-**

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវរៀបចំបង្កើតបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ។

## ជំពូកទី ៣

## របបសន្តិសុខសង្គម

**មាត្រា ៦.-**

មន្ត្រីរាជការស៊ីវិលអាចទទួលរបបសន្តិសុខសង្គមបាន លុះត្រាតែបំពេញតាមលក្ខខណ្ឌ ដូចបានចែងក្នុងច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌនីមួយៗ របស់មន្ត្រីរាជការស៊ីវិល ។

**មាត្រា ៧.-**

សមាជិក និងសិទ្ធិវន្ត **ប.ជ.ស.** ត្រូវបានទទួលពី **ប.ជ.ស.** នូវរបបសន្តិសុខសង្គម ដូចមានចែងក្នុងមាត្រា ២ នៃព្រះរាជក្រឹត្យនេះ ទៅតាមរបបដែលបានកំណត់ដោយរដ្ឋកន្លងមក និងដែលនៅជាធរមាន ។ ការកែប្រែតារាកាលិកនៃរបបសន្តិសុខសង្គមនេះ និងការផ្តល់បន្ថែមនូវតារាកាលិកដទៃទៀត ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃ **ប.ជ.ស.** ។

## ជំពូកទី ៤

## មូលនិធិសម្រាប់ទ្រទ្រង់របបសន្តិសុខសង្គម

**មាត្រា ៨.-**

មូលនិធិសម្រាប់ទ្រទ្រង់លើរបបសន្តិសុខសង្គមមានប្រភពមក ពីថវិការដ្ឋ ប្រាក់ភាគទានរបស់មន្ត្រីរាជការស៊ីវិល និវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ និងអ្នកនៅក្នុងបន្ទុករបស់ជនទាំងនេះ និងផលចំណេញបានពីការវិនិយោគ និងជំនួយមនុស្សធម៌ ពីប្រភពផ្សេងៗទៀត ។

**មាត្រា ៩.-**

រាជរដ្ឋាភិបាល មន្ត្រីរាជការស៊ីវិល និវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ និងអ្នកនៅក្នុងបន្ទុករបស់ជនទាំងនេះ ត្រូវមានកាតព្វកិច្ចបង់ភាគទានសម្រាប់ **ប.ជ.ស.** ទៅតាមអត្រាភាគទានលើបៀវត្សសរុប ដែលត្រូវកំណត់ឡើងនៅក្នុងអនុក្រឹត្យ ។

## ជំពូកទី ៥

## អន្តរប្បញ្ញត្តិ

**មាត្រា ១០.-**

ការគ្រប់គ្រង និងការផ្តល់របបសន្តិសុខសង្គមដែលនៅជាធរមាន សម្រាប់មន្ត្រីរាជការស៊ីវិល និវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ និងអ្នកនៅក្នុងបន្ទុករបស់ជនទាំងនេះ ត្រូវបន្តអនុវត្តរហូតដល់ **ប.ជ.ស.** ដំណើរការ ។

**មាត្រា ១១.-**

និយោជក និងនិយោជិតនៃសហគ្រាសសាធារណៈដែលបានបង់ភាគទានជូនរដ្ឋ ត្រូវបន្តអនុវត្តរបបសន្តិសុខសង្គម ដូចមន្ត្រីរាជការស៊ីវិល រហូតដល់មានបទប្បញ្ញត្តិថ្មី ។

## ជំពូកទី ៦

## អវសានប្បញ្ញត្តិ

**មាត្រា ១២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១៣.-**

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា តទៅ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០៨

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

**បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ**

សូមឡាយព្រះហស្តលេខា នស.០៨០១.០៤០

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

លេខ : ៥៥ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែ មករា ឆ្នាំ២០០៨

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**